# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១៣-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៣៨ ស្តីពីការតែងតាំងឯកឧត្តម **ខេង ស្វមេធ** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៤១៧

១៣-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គីម ជុងស៊ុង** (KIM JUNG SUNG) សញ្ជាតិដើមកូរ៉េ កើតនៅទីក្រុង Sea dacmun-ga, Seoul ប្រទេសកូរ៉េ ៤១៨

១៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤២ ស្តីពីការតម្លើងថ្នាក់ និងតម្លើងឋានន្តរស័ក្តិ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជូនមន្ត្រីរាជការ របស់ក្រសួងស្ថាប័ន ៤១៩

១៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤៣ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ជូនចំពោះអស់លោក ចំនួន ០២ រូប ៤២២

១៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤៤ ស្តីពីការប្រោសព្រះរាជទានចំពោះលោក KIM MYUNG IL នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤២៣

១៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤៥ ស្តីពីការតែងតាំង ឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៤២៤

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

២១-០១-២០០៩ -អនុក្រឹត្យលេខ ២២អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគដែលស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស ៤២៥

២០-០១-២០០៩ -អនុក្រឹត្យលេខ ៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤២៩

២០-០១-២០០៩ -អនុក្រឹត្យលេខ ៥៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣០

២០-០១-២០០៩ -អនុក្រឹត្យលេខ ៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣២

២០-០១-២០០៩ -អនុក្រឹត្យលេខ ៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៣
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៤
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៥
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៣៦
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៧
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៨
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៣៩
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤០
២០-០១-២០០៩ -អនុក្រឹត្យលេខ ៦៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៤១
២១-០១-២០០៩ -អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៤២
២២-០១-២០០៩ -អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៤៤
២២-០១-២០០៩ -អនុក្រឹត្យលេខ ៧១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៤៥
២២-០១-២០០៩ -អនុក្រឹត្យលេខ ៧២ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៤៤៦

## ២-សេចក្តីសំរេច

២១-០១-២០០៩ -សេចក្តីសំរេចលេខ ០៦ សសរ ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ៤៤៧

## ៣-សារាចរណែនាំ

២០-០១-២០០៩ -សារាចរណែនាំលេខ ០១ សរណន ស្តីពីការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ៤៥០

## III-ភាគខាងបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៧-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៨៧៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស-អេ រុន ខនគ្រិត ផារត** ៤៥២
១៧-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៨៨០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដេន** ៤៥៤
១៧-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៨៨១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូ ហ្គោលដេន ទើលដ៍** ៤៥៦

១៧-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៨៨២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីល ជុង ខនស្ត្រាក់សិន** ៤៥៨

១៧-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៨៨៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡេង-អ៊ី អ៊ិនដាសស្ទ្រៀល ខូ អិលធីឌី** ៤៦០

១៧-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៨៨៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិន.ត៊ី.ប៊ី.ខូ អិលធីឌី** ៤៦២

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ខេង សុមេធ** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ : ៣៩ ច.ល

ជូនចំពោះ

៣រល.០១០៩.០៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់ លោក **គីម ជុងស៊ុង** ( KIM JUNG SUNG ) សញ្ជាតិដើមកូរ៉េ កើតនៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ នៅទីក្រុង Sea dacmun-ga , Seoul ប្រទេសកូរ៉េ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៤ល.០៩០១.០៤០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៤១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងថ្នាក់មន្ត្រីរាជការក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន គិតពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៨ ដូចមានរាយនាមខាងក្រោម :

| ក្រសួងធនធានទឹក និងឧតុនិយម | | | |
|---|---|---|---|
| ១ | ឯកឧត្តម ឌង់ សារឿត | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ២ | ឯកឧត្តម ទេង សាខុន | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៣ | ឯកឧត្តម ស៊ិន ធុនី | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៤ | ឯកឧត្តម ប៊ុន ធោន | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS

| | | | |
|---|---|---|---|
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | |
| ១ | ឯកឧត្តម **ត្រាំ អ៊ីវតឹក** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | |
| ១ | ឯកឧត្តម **យឹម សារិទ្ធ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| **ក្រសួងកិច្ចការនារី** | | | |
| ១ | ឯកឧត្តម **ឡេង ណារ៉ាល់** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| **ក្រសួងយុត្តិធម៌** | | | |
| ១ | ឯកឧត្តម អង្គ វង្សវឌ្ឍានា | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ២ | ឯកឧត្តម ប៊ុក ម៉ាន់នី | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |

**មាត្រា ២** : តម្លើងថ្នាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គិតពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៨ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម **នុង ធីន** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ២ | ឯកឧត្តម **នឹម ចំនួនតារា** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៣ | ឯកឧត្តម **មាស គីមហេង** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៤ | ឯកឧត្តម **ហោ ណារ៉ាបូរ៉ា** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៥ | ឯកឧត្តម **ហ៊ុល ផានី** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៦ | ឯកឧត្តម **ហែម ហេង** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ |
| ៧ | លោកជំទាវ **នុច ផានី** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ |
| ៨ | ឯកឧត្តម **ហែម សាវឿម** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ |
| ៩ | ឯកឧត្តម **ស៊ា កុសល** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ |
| ១០ | ឯកឧត្តម **ជុំ សុន្ទរី** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ |
| ១១ | ឯកឧត្តម **ចាន់ គីស៊ីម** | ពីឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ |

**មាត្រា ៣** : តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល តាមកម្រិតសញ្ញាប័ត្រ ជូនមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| **ក្រសួងយុត្តិធម៌** | | | |
| ១ | ឯកឧត្តម **ជួន តេវ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | |
| [illegible] | ឯកឧត្តម **សោម សុគន្ធ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| ក្រសួងកិច្ចការនារី | | | |
|---|---|---|---|
| ១ | ឯកឧត្តម សឿ ម៉ុនឋារ | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា ៤** : មន្ត្រីដែលត្រូវបានតម្លើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ៣ ខាងលើត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០១.០៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩

លេខ : ៤៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីធិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ជូនចំពោះ :

១-លោក លឹម សុខារស្មី
២-លោក គុជ ស៊ីនិត

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣ណ.០៩០១.០៤៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩

លេខ : ៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោក KIM MYUNG IL

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៩០១.០៤៤

លេខៈ ៤៥ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩

រាជធានីភ្នំពេញ ថ្ងៃទី ... ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

យុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឯម សំណាង**

២- ឯកឧត្តម **សរ សិទ្ធិ** ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ : ៤៤ ច.ល

ជូនចំពោះឈ្មោះចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៩

**អគ្គលេខាធិការនៃរាជរដ្ឋាភិបាល**

**ស៊ុន ចាន់ថុល**

៣៩ល.០៩០១.០៤៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ដែលស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យកែសំរួលលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញសេចក្តីសំរេចលេខ ៣២ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# សម្រេច

**មាត្រា១ :** ត្រូវបានបង្កើតគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ដែលជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលកើតមានឡើង ចំពោះអ្នកវិនិយោគ សំដៅកែលំអបន្ថែមបរិយាកាសសម្រាប់ការវិនិយោគ និងជំរុញឱ្យការអនុវត្តគម្រោងវិនិយោគប្រព្រឹត្តទៅប្រកបដោយ ជោគជ័យ ។

គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ បំពេញភារកិច្ចនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស ដោយមិនដោះស្រាយនូវបញ្ហាដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការដោះស្រាយបញ្ហា នៃតំបន់សេដ្ឋកិច្ចពិសេស ដែលកំណត់ដោយអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៥ នោះឡើយ ។

**មាត្រា២ :** គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| ១. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២. លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ | អនុប្រធានទី១ |
| ៣. ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធានទី២ |
| ៤. ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥. ឯកឧត្តម ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៦. ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧. ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩. ឯកឧត្តម សុខ ចិន្តា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិកប្រចាំការ |
| ១០. ឯកឧត្តម ចន្ទ័ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១. ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១២. ឯកឧត្តម ម៉ឹង សំផន រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១៣. ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤. ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៥. ឯកឧត្តម សយ ស៊ីផុន រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៦. លោកជំទាវ ចន្ទ័ សុធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |

១៧. ឯកឧត្តម នូ សុវត្ថិ រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១៨. ឯកឧត្តម នាយឧត្តមសេនីយ៍ គន់ គីម អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ សមាជិក

១៩. ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ សមាជិក

២០. ឯកឧត្តម ឧត្តមសេនីយ៍ សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២១. ឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ
និងជាអគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សមាជិក

២២. ឯកឧត្តម សំ សុផល អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

២៣. ឯកឧត្តម គី តិច មេធាវីរាជរដ្ឋាភិបាល សមាជិក

២៤. អភិបាលរាជធានីភ្នំពេញ-ខេត្ត សមាជិក

២៥. ឯកឧត្តម ឯម សុភ័ណ្ឌ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

២៦. ឯកឧត្តម សួន សិទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា លេខាធិការ

**មាត្រា៣** : គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានតួនាទី និងភារកិច្ចដូចតទៅ ៖

-ជាយន្តការទទួលពាក្យបណ្តឹងតវ៉ា និងដោះស្រាយបញ្ហាដែលស្នើសុំដោយអ្នកវិនិយោគ

-ដោះស្រាយនូវរាល់បញ្ហាជាបន្ទាន់ទាំងឡាយរបស់អ្នកវិនិយោគ ដែលមានឥទ្ធិពលប៉ះពាល់ដល់បរិស្ថានវិនិយោគ និងសេដ្ឋកិច្ចជាតិ ដែលហួសពីសមត្ថកិច្ចរបស់អនុគណៈកម្មាធិការវិនិយោគរាជធានីភ្នំពេញ-ខេត្ត ឬគណៈកម្មាធិការវិនិយោគកម្ពុជា ទាំងលើទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពច្បាប់ ។

-សហការជាប្រចាំជាមួយ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា និងស្ថាប័នមានសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងបញ្ហាវិនិយោគ ។

-ធ្វើរបាយការណ៍ អំពីសកម្មភាពការងាររបស់គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤** : គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ មានទីតាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិប្រើប្រាស់ត្រា និងប្រើប្រាស់ថវិកាចំណាយ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ លេខាធិការដ្ឋាន នៃគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានលេខាធិការមួយរូប ជាអ្នកដឹកនាំ អមដោយជំនួយការមួយចំនួន តាមការចាំបាច់ ។

**មាត្រា៥** : សមាជិកទាំងអស់នៃគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន អនុប្រធាន តាមការប្រគល់សិទ្ធិ។ សម្រាប់ករណីពិសេស គណៈកម្មាធិការមានសិទ្ធិអញ្ជើញឱ្យចូលរួមប្រជុំផងដែរ នូវរាល់តំណាងក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ ។

**មាត្រា៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី

ក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៦

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធានជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម នៅសាលាបឋមសិក្សាប្រភ្នំ ស្ថិតក្នុងឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-លោក | **សួន** | **ម៉ុនថន** | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ២០.០០០ ដុល្លារ |
| ២-អ្នកស្រី | **ឃុត** | **ណារ៉ាត់** | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១៥.៣០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ២៧ រូប ស្ថិតក្នុងក្រសួង ស្ថាប័ន ដែលជាអង្គភាពសម្ព័ន្ធមេត្រីភាព ជាមួយយោធភូមិភាគទី៥ ដែលបានឧបត្ថម្ភអំណោយជាថវិកា និងសម្ភារៈយ៉ាងច្រើនជូនដល់យោធភូមិភាគទី៥ សម្រាប់ជួយពង្រឹងកម្លាំងកងទ័ពក្នុងកិច្ចការពារបូរណភាពទឹកដីតាមបណ្តោយព្រំដែនភាគខាងលិច ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ជុំ** | **យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ២-ឯកឧត្តម | **កើត** | **មៀច** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល |
| ៣-ឯកឧត្តម | **ជួប** | **សំអាត** | អគ្គនាយករដ្ឋបាល ហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៤-ឯកឧត្តម | **ចាន់** | **ដារ៉ុង** | អគ្គនាយកបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៥-លោក | **អ៊ាន់** | **ផាន់នី** | នាយអធិការដ្ឋានរដ្ឋបាល ជលផលខាងជើងបឹងទន្លេសាប |
| ៦-លោក | **ហ៊ាន** | **ត្រេង** | អនុប្រធាននាយកដ្ឋានសវនកម្មទី៣ អគ្គនាយកដ្ឋានពន្ធដារ |
| ៧-លោក | **ហេង** | **ណារិទ្ធ** | ប្រធានការិ.សវនកម្មទី៣ អគ្គនាយកដ្ឋានពន្ធដារ |
| ៨-លោក | **ហុង** | **ហ៊ី** | នាយអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប |
| ៩-លោក | **ពុំ** | **សុថា** | នាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ |
| ១០-លោក | **ឡុង** | **គន** | នាយអធិការដ្ឋានរដ្ឋបាលជលផលមេគង្គ |
| ១១-លោក | **សុង** | **ហុង** | នាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ |

១២-លោក ហេង ពិសិដ្ឋ នាយខណ្ឌរដ្ឋបាលជលផលបាត់ដំបង
១៣-លោក ង សែនសិរីវឌ្ឍន៍ ប្រធានការិ.ផែនការ និង គណនេយ្យរដ្ឋបាលជលផល
១៤-លោក មាស ម៉ិនថុង អគ្គនាយករង រតនាគារជាតិ
១៥-លោក ស្រី សាមិត ប្រធាននាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ

**ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

១-ឯកឧត្តម ឯក ផាំ ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក ក្រសួងអភិវឌ្ឍន៍ជនបទ
២-លោក អ៊ឹម លក្ខិណា អនុប្រធានការិ.សវនកម្មសហគ្រាស អគ្គនាយកដ្ឋានពន្ធដារ
៣-លោក ប៉ក ចាន់បូរិន អនុប្រធានការិ.សវនកម្មទី៣ អគ្គនាយកដ្ឋានពន្ធដារ
៤-លោក សេង ភ្លឹប មន្ត្រីនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល
៥-លោកវេជ្ជ. ឈុំ វណ្ណារិទ្ធ ប្រធានមន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ
៦-លោកគ្រូពេទ្យ គិន វ៉ាន់ឌី អនុប្រធាននាយកដ្ឋានថវិកា និងហិរញ្ញវត្ថុក្រសួងសុខាភិបាល
៧-លោក ឆួន សុខហេង អនុប្រធានសាខាពន្ធដារ ខណ្ឌទួលគោក
៨-លោក លឹម ចំន្ទថៃ ប្រធានរតនាគារ ខេត្តពោធិសាត់
៩-លោក ឃុត ស៊ីនី ប្រធានរតនាគារ ខេត្តបន្ទាយមានជ័យ
១០-លោក ស៊ីវុន ខេមារុន ប្រធានរតនាគារ ខេត្តបាត់ដំបង
១១-លោក ហៀង សុវណ្ណារ៉ា អនុប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
១២-លោក ប៊ុក គីមយ៉ុង អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបាត់ដំបង

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ធំ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៥ រូប ដែលបានចូលរួមចំណែកក្នុងការកសាងសមិទ្ធផលនានា ជារូមមាន : អគារសិក្សា ០២ខ្នង មាន ១០បន្ទប់ នៅអនុវិទ្យាល័យសម្តេច **ជា ស៊ីម ប្រឡាយ** ០១ខ្នង មាន០៥បន្ទប់ នៅសាលាបឋមសិក្សាកំព្រាល ០១ខ្នង មាន០៥បន្ទប់ នៅសាលាបឋមសិក្សាអន្លង់ព្រីង និងព្រះវិហារវត្តមុន្នីវង្ស ស្ថិតក្នុងឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-ឯកឧត្តម | **ឆាំ សុជាតិវង្ស** | ថវិកាចំនួន ៤៦.០០០ ដុល្លារ |
| ២-លោកជំទាវ | **អ៊ួន សុវណ្ណារិន្ទ** ភរិយា ឯកឧត្តម **ឆាំ សុជាតិវង្ស** | ថវិកាចំនួន ៩៩.០០០ ដុល្លារ |
| ៣-លោក | **គ្រួច សំរឿន** | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤-លោក | **អ៊ឹម សំអុល** | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៥-អ្នកស្រី | **អ៊ឹម វណ្ណនី** | ថវិកាចំនួន ១០.០០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគធនធានជួយកសាងកុដិ ០១ខ្នង មានកំពស់ ០២ជាន់ នៅវត្តគាតថាវង្ស ស្ថិតក្នុងឃុំត្រពាំងសាលាខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | ឌឹន | សាន | ព្រះចៅអធិការវត្តគាតថាវង្ស | បច្ច័យ ចំនួន ១០.០០០ ដុល្លារ |
| ២-ព្រះតេជគុណ | ម៉ៅ | ប្រុស | ព្រះគ្រូសូត្រឆ្វេងវត្តគាតថាវង្ស | បច្ច័យ ចំនួន ១០.០០០ ដុល្លារ |
| ៣-ព្រះតេជគុណ | ឃៀក | ប៊ី | គង់នៅប្រទេសអូស្ត្រាលី | បច្ច័យ ចំនួន ១០.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | ចាន់ | សាមន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ៥.២០០ ដុល្លារ |
| ២-លោក | ស៊ឹម | សុនធីម | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ៥.១៥០ ដុល្លារ |
| ៣-ឧបាសិកា | ប៉ែន | សំអឿន | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ៥.១០០ ដុល្លារ |

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសក | នាង | ហឿន | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០៣០ ដុល្លារ |
| ២-ឧបាសក | យង់ | ផាន | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០១០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

១១៦៧៤១១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តពោធិសត្តារាម ស្ថិតក្នុងឃុំសត្វពង ស្រុកឈូក ខេត្តកំពត ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ពីន** | **សូទេត** | ព្រះចៅអធិការវត្តពោធិសត្តារាម | បច្ច័យ ចំនួន១១.០០០ ដុល្លារ |
| ២-លោក | **ខុន** | **នៅ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន១៩.៧៧២ ដុល្លារ |
| ៣-ឧកញ៉ា | **អ៊ុយ** | **ស្មើខ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ១០.០០០ ដុល្លារ |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| -លោក | **អោម** | **យឿន** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ៥.៤៨០ ដុល្លារ |

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសក | **ស្នូខ** | **លី** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ២.៥០០ ដុល្លារ |
| ២-អ្នកស្រី | **គីម** | **ខាន់ឌី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ២.២៥០ ដុល្លារ |
| ៣-លោក | **ឌួន** | **សារី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ២.១៥០ ដុល្លារ |
| ៤-អ្នកស្រី | **ឃឹម** | **ចន្ថា** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.២៥០ ដុល្លារ |
| ៥-លោក | **ថាន** | **សែត** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០៣០ ដុល្លារ |
| ៦-ឧបាសក | **សែម** | **ហ៊ំ** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០៥ ដុល្លារ |
| ៧-ឧបាសក | **ភួយ** | **ញៀន** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០០ ដុល្លារ |
| ៨-ឧបាសក | **កែវ** | **នឹម** | សប្បុរសជននៅខេត្តកំពត | ថវិកា ចំនួន ១.០០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **ស្ថាបនាជាតិ ថ្នាក់សំរិទ្ធ** ដល់សប្បុរសជនចំនួន០៤ រូបមានចិត្តសប្បុរសជួយឧបត្ថម្ភថវិកាផ្ទាល់ខ្លួនដែលមានទឹកប្រាក់សរុបចំនួន ១៤.៥១៨ ដុល្លា (ដប់បួនពាន់ ប្រាំរយដប់ប្រាំបី ដុល្លាសហរដ្ឋអាមេរិកគត់) ដើម្បីកសាងប៉ុស្តិ៍នគរបាលសំយោង នៃវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៦០៩ នៅឃុំសំយោង ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | លោក | អោម | ចន | ប្រធាននាយកដ្ឋានពន្ធដាររាជធានីភ្នំពេញ បានឧបត្ថម្ភថវិកា ចំនួន ៤.០០០ ដុល្លា |
| ២ | លោក | ជុំ | ចណ្ណី | អនុប្រធាននាយកដ្ឋានពន្ធដាររាជធានីភ្នំពេញ បានឧបត្ថម្ភថវិកា ចំនួន ៤.៥០០ ដុល្លា |
| ៣ | លោក | ខួន | សុធាទី | អនុប្រធាននាយកដ្ឋានពន្ធដាររាជធានីភ្នំពេញ បានឧបត្ថម្ភថវិកា ចំនួន ៣.០០០ ដុល្លា |
| ៤ | លោក | យឹម | ហ្វិត | នាយកក្រុមហ៊ុនត្រេឌីងលីមីតធីត បានឧបត្ថម្ភថវិកា ចំនួន ៣.០១៨ ដុល្លា |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១ និងមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

១១៦០៨១១

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអ្នកជំនាញការ និងគ្រូពេទ្យស្ម័គ្រចិត្ត ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ លើវិស័យព្រៃឈើនិងវិស័យសុខាភិបាល សម្រាប់មន្ត្រីរដ្ឋបាលព្រៃឈើ នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

១-លោក **Tsuburaya Hiroyuki** អ្នកជំនាញការជនជាតិជប៉ុន

២-លោកស្រី **Park Yoon Gu** គ្រូពេទ្យស្ម័គ្រចិត្ត នៃសាធារណរដ្ឋកូរ៉េ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

១១៧៧១១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនអង្គការ ចំនួន០២ ដែលបានឧបត្ថម្ភថវិកាជួយកសាងអគារសម្រាប់ស្ត្រីរង់ចាំសម្រាលកូន ចំនួន ០១ ខ្នង នៅមណ្ឌលសុខភាពឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានខាងក្រោម :-

១-**អង្គការ** O.T.E.S Canada ឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ

២-**អង្គការ** A.O.I Alliance ឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

១១៦៧០៥១១

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តព្រៃរោង ស្ថិតក្នុងឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ម៉ម** | **តារុន** | ព្រះចៅអធិការវត្តព្រៃរោង | បច្ច័យ ចំនួន ១០.៤០០ ដុល្លារ |
| ២-លោក | **តឹង** | **ស៊ុន្ឡាយ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ១១.៦០០ ដុល្លារ |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | **ទឹម** | **សាមី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ៥.៧០០ ដុល្លារ |
| ២-ឧបាសិកា | **ហ៊ី** | **ហ៊ួ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ចំនួន ៥.៦០០ ដុល្លារ |
| ៣-លោក | **សែង** | **ឃាង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា ចំនួន ៥.៥៨០ ដុល្លារ |
| ៤-លោក | **ណុប** | **ផែម** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា ចំនួន ៥.៤៧០ ដុល្លារ |

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **សៅ** | **ឌី** | គង់នៅវត្តព្រៃរោង | បច្ច័យ ចំនួន ១.៣០០ ដុល្លារ |
| ២-ឧបាសិកា | **ខៀវ** | **លន់** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា ចំនួន ១.៣៨០ ដុល្លារ |
| ៣-ឧបាសក | **ឃុន** | **ជួន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា ចំនួន ១.២៦០ ដុល្លារ |
| ៤-លោក | **អ៊ុក** | **ណារំ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា ចំនួន ១.២៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
